នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសង |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 06-Feb-2014, 14:57
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ការឆ្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបនៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង ០០២/០១ នៅក្នុងសំណុំរឿង០០២/០២

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSE

## *I. សេចក្តីផ្តើម*

១- នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") សម្រេចថា: "ក) ភស្តុតាងទាំងអស់ដែលបានទទួលយកនៅក្នុងសំណុំរឿង០០២/០១ ហើយដែលបានចាត់តាំងលេខ E3 នឹងត្រូវបានពិចារណាថា បានដាក់យ៉ាងត្រឹមត្រូវនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីសវនាការនាពេលអនាគតទាំងអស់ ទាក់ទងនឹងបទចោទដែលនៅសល់ និង ខ) សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្តាប់សវនាការនៅក្នុងសំណុំរឿង០០២/០១ អាចនឹងត្រូវបានកោះហៅឡើងវិញ នៅក្នុងសំណុំរឿង០០២/០២ តែក្នុងករណីភាគីស្នើសុំបានបំពេញទៅតាមគុណការដែលថា ការសួរបន្ថែមគឺដើម្បីផលប្រយោជន៍យុត្តិធម៌តែប៉ុណ្ណោះ"[1]។

២- ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា និងបានស្នើសុំឱ្យអង្គជំនុំជម្រះបដិសេធចោលការស្នើសុំនេះទាំងអស់[2]។

៣- ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៤ មេធាវីការពារក្តី នួន ជា បានឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដោយថ្លែងថា "មេធាវីការពារក្តីបានយល់ស្របជាមួយសហព្រះរាជអាជ្ញាថា ឯកសារដែលបានទទួលយកក្នុងសំណុំរឿង០០២/០១ គួរតែអាចទទួលយកបានសម្រាប់សំណុំរឿង០០២/០២"[3]។ មេធាវីការពារក្តី នួន ជា ក៏បានយល់ស្របមួយផ្នែកជាមួយការសម្រេចដែលបានស្នើសុំពាក់ព័ន្ធនឹងការស្តាប់សវនាការសាក្សីឡើងវិញ។ ពួកគាត់បានព្រមព្រៀងថា "ភាគីណាក៏ដោយក៏មានសិទ្ធិស្នើសុំបុគ្គលណាម្នាក់ ដែលបានឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ក្នុង

[1] **E302** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង០០២/០១ ទៅក្នុងសំណុំរឿងលេខ០០២/០២, ១៥ មករា ២០១៤ ("សេចក្តីសន្និដ្ឋានរបស់ កសព"), កថាខណ្ឌ១។

[2] **E302/1** (ចម្លើយរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹង "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង០០២/០១ ទៅក្នុងសំណុំរឿងលេខ០០២/០២"), ២៧ មករា ២០១៤, ("ចម្លើយតបរបស់ ខៀវ សំផន)។

[3] **E302/2** ចម្លើយតបរបស់ នួន ជា ចំពោះសារណារបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការប្រើភស្តុតាងពីសំណុំរឿង០០២/០១ នៅក្នុងសំណុំរឿង០០២/០២, ៣ កុម្ភៈ ២០១៤ ("ចម្លើយតបរបស់ នួន ជា"), កថាខណ្ឌ៣។

សំណុំរឿង០០២/០១ ឲ្យចូលមកបង្ហាញខ្លួនក្នុងសំណុំរឿង០០២/០២ បានដែរ”[4] ប៉ុន្តែបានធ្វើការសន្និដ្ឋានថា នៅពេលពិចារណាថាតើសាក្សីណាម្នាក់គួរត្រូវកោះហៅមកធ្វើសវនាការឡើងវិញ អង្គជំនុំជម្រះគួរពិចារណាថាតើការធ្វើសវនាការឡើងវិញនោះ នឹងបានជាជំនួយដល់ការវាយតម្លៃអំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មក្នុងសំណុំរឿង០០២/០២ ដែរឬទេ។

៤- ថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៤ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ចម្លើយតបមួយទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងការសម្រេចដែលបានស្នើសុំ[5]។

## *II. អំណះអំណាង*

### *ក. សំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ ជាសំណុំរឿងតែមួយ*

៥- ចម្លើយតបរបស់មេធាវីការពារក្តី ខៀវ សំផន ធ្វើមិនដឹងមិនឮចំពោះទំនាក់ទំនង រវាងសំណុំរឿង ០០២/០១ និងសំណុំរឿង០០២/០២ ហើយនីតិវិធីដែលអង្គជំនុំជម្រះសាលាដំបូងបានរំពឹងទុកនៅក្នុងការអនុវត្តចំពោះរឿងក្តីដែលមានការពាក់ព័ន្ធគ្នាយ៉ាងខ្លាំងទាំងពីរនេះ[6]។ រឿងក្តីទាំងពីរកើតចេញពីកិច្ចស៊ើបសួរតែមួយ ជាលទ្ធផល ចេញបានជាឯកសារចោទប្រកាន់តែមួយ គឺដីកាដំណោះស្រាយនៃសំណុំរឿង០០២។ ដោយមិនគិតពីដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី បទចោទទាំងប៉ុន្មានដែលបានរៀបរាប់យ៉ាងលម្អិតនៅក្នុងដីកាដំណោះស្រាយនេះ បង្កើតបានជាផ្នែកនៃសំណុំរឿងតែមួយ[7]។ មេធាវីការពារក្តី ខៀវ សំផន អះអាងថា នីតិវិធីទាំងអស់ដែលបានអនុវត្តនៅក្នុងសំណុំរឿង០០២/

[4] **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ១៨ តុលា ២០១១ (“ការពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី”), កថាខណ្ឌ៤។

[5] **E302/3** ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង០០២/០១ ទៅក្នុងសំណុំរឿងលេខ០០២/០២, ៣ កុម្ភៈ ២០១៤ (“ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី”)។

[6] **E302/1** (ចម្លើយរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ទៅនឹង “សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្តីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មី ពីសំណុំរឿង០០២/០១ ទៅក្នុងសំណុំរឿងលេខ ០០២/០២”), ២៧ មករា ២០១៤, កថាខណ្ឌ ៣៤។

[7] Jean Pradel, “Manuel de Procédure Pénale” (2006) 13th Edition, p.476: “La procédure d’instruction est écrite […] Tous les actes de l’instruction, qu’il s’agisse des actes d’investigation ou des actes de juridiction, donnent lieu à un écrit, signé du juge (ou du président de la chambre de l’instruction) et du greffier, voire du déposant lorsque l’acte est un interrogatoire ou une audition. Tous les actes sont réunis dans un *dossier* dont disposera le président de la juridiction de jugement.”

០១ ត្រូវតែយកមកអនុវត្តជាថ្មីឡើងវិញនៅក្នុងសំណុំរឿង០០២/០២ទាំងមូល[8]។ ពួកគេសន្និដ្ឋានថា ការណ៍នេះចាំបាច់សម្រាប់ការផលិតឡើងវិញដោយភាគីនូវបញ្ជីភ័ស្តុតាង និងសាក្សី (ថ្មី និងរួមបញ្ចូលគ្នា) សេចក្តីសន្និដ្ឋានទាក់ទងនឹងភាពអាចទទួលយកបាននៃភ័ស្តុតាងរួមទាំងភ័ស្តុតាងដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿង០០២/០១ និងការដេញដោលឡើងវិញ ចំពោះសាក្សីដែលបានមកឆ្លើយបំភ្លឺរួចហើយចំពោះបញ្ហាដូចគ្នានេះ នៅក្នុងសំណុំរឿង០០២/០១[9]។ ការបកស្រាយរបស់មេធាវីការពារក្តី ខៀវ សំផន លើសេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី គឺមិនត្រឹមត្រូវទេ ហើយនឹងធ្វើឲ្យមានភ័ស្តុតាងជាន់គ្នាមិនចាំបាច់ដែលគេបានស្តាប់សវនាការ និងបានសាកល្បងដោយភាគីទាំងអស់រួចហើយ ចំពោះរឿងក្តីនៅស្ថិតនៅចំពោះមុខអង្គជំនុំជម្រះដដែលនេះ។

៦- ដូចដែលសំណុំរឿង០០២/០១ និងសំណុំរឿង០០២/០២ គឺជាផ្នែកតៗគ្នានៃសំណុំរឿងតែមួយ[10] ការអនុវត្តឡើងវិញនូវនីតិវិធី និងការសើរើសាឡើងវិញនូវភ័ស្តុតាងពីសំណុំរឿង០០២/០១ទាំងអស់ គឺមិនមានទាំងអាណត្តិសម្រាប់ធ្វើការកិច្ចនេះផង និងថែមទាំងមិនចាំបាច់ផង។ គោលជំហរនេះបានទទួលការគាំទ្រពីសំណាក់មេធាវីការពារក្តី នួន ជា[11] និងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី[12]។ ការព្យាយាមរបស់ ខៀវ សំផន ដើម្បីប្រៀបធៀបការសម្រេចដែលបានស្នើសុំនៅ ក្នុងករណីនៅពេលនេះ ទៅនឹងការផ្ទេរប្រតិចារឹកពីសំណុំរឿង០០១ មកសំណុំរឿង០០២/០១ គឺមិនត្រឹមត្រូវតាមច្បាប់ទេ ដោយសារថា នៅទីនេះ ជនជាប់ចោទមិនមែនជាភាគីក្នុងសំណុំរឿង០០១ទេ ដូច្នេះមិនទាន់មានឱកាសដេញដោលសាក្សីរបស់ភាគីបដិបក្ខ ដែលបានឆ្លើយបំភ្លឺនៅក្នុងសវនាការនោះនៅឡើយ[13]។

---

[8] **E302/1** ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌ១៥។

[9] *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌទី១០។

[10] **E163/5/1/9** ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការក្នុងសំណុំរឿង០០២/០១, ៣០ វិច្ឆិកា ២០១៣, កថាខណ្ឌ៣១ ដែលលើកយោង **ឯកសារ E124/7** ការពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី, កថាខណ្ឌ១០។ **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣ ("សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ"), កថាខណ្ឌ១៥។

[11] **E302/2** ចម្លើយតបរបស់ នួន ជា, កថាខណ្ឌ៣ "[គាំទ្រសំណើរបស់សហព្រះរាជអាជ្ញា] ស៊ីជាមួយសារណាស្តីពីវិសាលភាពរបស់ នួន ជា ដែលបានលើកអំណះអំណាងថា អង្គជំនុំជម្រះគប្បីពិចារណាភ័ស្តុតាងដែលមានអង្គហេតុនៅក្នុងដីកាដំណោះស្រាយទាំងមូលដែលត្រូវតែពាក់ព័ន្ធជាមួយការចោទប្រកាន់នៅក្នុងសំណុំរឿង០០២/០២"។

[12] **E302/3** ចម្លើយតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

[13] **E302/1** ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌ១៧។

## *ខ.* *ការសម្រេចតាមសំណើសុំត្រូវបានអង្គជំនុំជម្រះសម្រេចរួចហើយនៅក្នុងសេចក្តីសម្រេចកាលពីមុន*

៧- ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន បានពោលអះអាងថាសហព្រះរាជអាជ្ញាបានពឹងផ្អែកលើការបកស្រាយខុសអំពីគោលបំណងរបស់អង្គជំនុំជម្រះនៅក្នុងការបំបែកសំណុំរឿង០០២[14]។ ទោះបីជាយ៉ាងណាក៏ដោយ ផ្ទុយពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តី អង្គជំនុំជម្រះបានបញ្ជាក់ច្បាស់ថាភ័ស្តុតាងដែលបានលើកយកមកសម្អាងកាលពីនៅក្នុងសំណុំរឿងលេខ០០២/០១ គួរតែអាចយកទៅប្រើនៅក្នុងសំណុំរឿងលេខ០០២/០២បាន។ សំណុំរឿងលេខ០០២/០១ គឺមានបំណងចង់ "ផ្តល់ជូនជាមូលដ្ឋានគ្រឹះមួយសម្រាប់ឲ្យធ្វើការពិនិត្យឲ្យបានកាន់តែលម្អិតថែមទៀត ទៅលើបទចោទប្រកាន់និងទៅលើការចោទប្រកាន់ខាងអង្គហេតុទាំងឡាយដែលនៅសេសសល់ប្រឆាំងនឹងជនជាប់ចោទ នាពេលសវនាការក្រោយៗទៀត"[15]។ សេចក្តីថ្លែងនេះកាលពីមុន ធ្លាប់ទទួលបាននូវការគាំទ្រយ៉ាងច្បាស់លាស់ដោយក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន[16]។ មធ្យោបាយដែលប្រកបដោយតក្កភាពនិងដែលមានប្រសិទ្ធភាពបំផុតក្នុងការប្រើប្រាស់សំណុំរឿងលេខ០០២/០១ ដើម្បីធ្វើជា "មូលដ្ឋានគ្រឹះ" សម្រាប់សវនាការជំនុំជម្រះក្តីសម្រាប់ពេលខាងមុខទៀតនោះ គឺត្រូវទទួលយកនូវភ័ស្តុតាងនានា ដែលមកពីសវនាការជំនុំជម្រះក្តីនោះ ចូលទៅក្នុងសំណុំរឿងលេខ០០២/០២។

៨- ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន បានពោលអះអាងដោយមិនត្រឹមត្រូវថាសិទ្ធិក្នុងការសួរដេញដោលសាក្សីជំនាញនានា ទៅលើវិសាលភាពនៃសំណុំរឿងលេខ០០២ទាំងមូលនោះ គឺវាគ្រាន់តែជាសិទ្ធិដែលនៅក្នុងទ្រឹស្តីតែប៉ុណ្ណោះ[17]។ អង្គជំនុំជម្រះបានសម្រេចថាសាក្សីជំនាញនានា ត្រូវបានអនុញ្ញាតឲ្យធ្វើការ "សួរដេញដោលលើគ្រប់រាល់បញ្ហាទាំងអស់ដែលពួកគាត់បានដឹង ឬក្នុងវង្វង់វិស័យជំនាញរបស់ពួកគាត់ដែលទាក់ទងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿងលេខ០០២ទាំងមូល"[18]។

---

[14] **E302/1** Khieu Samphan Response, para. 19, 20: "Cette analyse est particulièrement erronée. Tout d'abord, si la Chambre a indiqué qu'il était prévu que le premier procès serve à poser le « fondement» pour l'examen des suivants, ce n'était certainement pas de la façon dont l'entendent les co-Procureurs."

[15] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី១០។

[16] ឯកសារលេខ **E163/5/1/9** ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ចំពោះសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១, ចុះថ្ងៃទី៣០ វិច្ឆិកា ២០១២, កថាខណ្ឌទី៣១។

[17] ឯកសារលេខ **E302/1** ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌទី២៤។

[18] ឯកសារលេខ **E215** សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញ, ចុះថ្ងៃទី៥ កក្កដា ២០១២, ត្រង់កថាខណ្ឌទី៤។ សូមអានផងដែរ ឯកសារលេខ **E284** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ, កំណត់សម្គាល់លេខ ៩ *ខាងដើម* ត្រង់កថាខណ្ឌទី៤៥ (i)។ឯកសារលេខ **E264/1** អនុស្សរណៈ៖ ការកំណត់កាលបរិច្ឆេទសម្រាប់អ្នកជំនាញលោក Phillip Short និងលោកស្រី Elizabeth Becker

ការណ៍នេះច្បាស់ដោយឈរលើមូលដ្ឋានគោលការណ៍ ដែលថាភស្តុតាងដែលមកពីសំណុំរឿងលេខ ០០២/០១ អាចត្រូវបានយកទៅប្រើនៅក្នុងសំណុំរឿងលេខ០០២/០២។ តាមការអនុវត្តជាក់ស្តែង ផ្ទុយពីការអះអាងរបស់ ខៀវ សំផន[19] សាក្សីជំនាញទាំងឡាយត្រូវបានអនុញ្ញាតឱ្យគេធ្វើការសួរដេញដោលទាក់ទងនឹងបញ្ហានានាដែលពាក់ព័ន្ធនឹងការចោទប្រកាន់ផ្សេងៗដែលនឹងត្រូវលើកឡើងតែនៅក្នុងសវនាការជំនុំជម្រះក្តីបន្តបន្ទាប់ទៅទៀតតែប៉ុណ្ណោះ[20]។ ដូចសេចក្តីសន្និដ្ឋានពីមុនៗ អង្គជំនុំជម្រះអនុញ្ញាតផងដែរឱ្យភាគីទាំងអស់សួរសំណួរដល់សាក្សីដែលមានវ័យចំណាស់នៅលើបញ្ហាដែលស្ថិតក្នុងបរិបទនៃសំណុំរឿង០០២ទាំងមូល[21]។

## *គ. សំណើនេះនឹងមិនមានផលប៉ះពាល់ ទៅលើបទដ្ឋាននៃភស្តុតាង ដែលបានតម្រូវនៅក្នុង សំណុំរឿងលេខ០០២/០២ឡើយ*

៩- ក្រុមមេធាវីការពារក្តី ខៀវ សំផន បានតវ៉ាថាសំណើដែលសុំឱ្យសម្រេចនឹងត្រូវកាត់បន្ថយ បទដ្ឋាននៃភស្តុតាងដែលបានតម្រូវនៅក្នុងសំណុំរឿងលេខ០០២/០២ ហើយ ជូនសេចក្តីសន្និដ្ឋានថា ការយកភស្តុតាងមកប្រើបន្តទៀត មុខជានឹងរកផ្លូវជៀសឱ្យផុតពីវិធានស្តីពីនីតិវិធី ដែលតម្រូវឱ្យមានឯកសារពាក់ព័ន្ធ និងការសួរដេញដោលចំពោះអង្គហេតុនានាដែលត្រូវបានចោទប្រកាន់ នៅក្នុងសំណុំរឿងលេខ០០២/០២[22]។ ការអះអាងនេះ គឺមិនត្រឹមត្រូវឡើយ។ នៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាមិនបានឱ្យអង្គជំនុំជម្រះវាយតម្លៃលើភស្តុតាងនៅចំពោះមុខ ដោយមានការពិនិត្យឯកសារបានតិចជាងឯកសារដែលមាននៅក្នុងសំណុំរឿង។ សំណើរបស់សហព្រះរាជអាជ្ញាគ្រាន់តែ

---

និងការលើកពេលសម្រាប់សាក្សីទាក់ទងនឹងអង្គហេតុ រហូតដល់ពេលចេញសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី, ចុះថ្ងៃទី២៦ កុម្ភៈ ២០១៣ (“ការកំណត់កាលបរិច្ឆេទសម្រាប់អ្នកជំនាញ”) ត្រង់កថាខណ្ឌទី២។

[19] ឯកសារលេខ **E302/1** ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌទី២៤។

[20] ឯកសារលេខ **E215** សេចក្តីសម្រេចស្តីពីការតែងតាំងអ្នកជំនាញ, កថាខណ្ឌទី៤។ ឯកសារលេខ **E284** សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីលើកទីពីរ, កថាខណ្ឌទី៤៥ (i)។ ឯកសារលេខ **E264/1** ស្តីពីការកំណត់កាលបរិច្ឆេទសម្រាប់អ្នកជំនាញ, កថាខណ្ឌទី២។ ឯកសារលេខ **E194** Memorandum: Order of Witnesses until Decision on Severance, 26 February 2013 at para. 2; ឯកសារលេខ **E1/18.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ចុះថ្ងៃទី៧ ធ្នូ ២០១១, ទំព័រ២៨ នៅម៉ោង ២៨:១៧-២៩:៩ , និងម៉ោង ៥០:៥-៩។ សូមអានផងដែរ ឯកសារលេខ **E145** សេចក្តីជូនដំណឹងស្តីពីការសម្រេចបញ្ចប់របស់ អង្គជំនុំជម្រះសាលាដំបូង លើញត្តិនានាដែលនៅសេសសល់ មុនពេលសវនាការ និងការណែនាំបន្ថែម ដល់មេធាវីនាំមុខនៃដើម្បបណ្តឹងរដ្ឋប្បវេណី, ចុះថ្ងៃទី២៩ វិច្ឆិកា ២០១១, ទំព័រ៣។

[21] ឯកសារលេខ **E194** អនុស្សរណៈស្តីពីលំដាប់នៃសាក្សីសម្រាប់ផ្នែកនៃសវនាការលើសំណុំរឿង០០២/០១ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២។

[22] ឯកសារលេខ **E302/1** Khieu Samphan Response, para. 28: “…sous couvert de prétendus gains de temps, ne cesse de suggérer de faux raccourcis et des interprétations portant atteinte à la qualité du débat judiciaire.”

បានផ្ទុះបញ្ហាំងការពិតដែលថា ភ័ស្តុតាងដែលអង្គជំនុំជម្រះបានទទួលយក គឺពាក់ព័ន្ធនឹងរឿងក្តីទាំងមូល ហើយថា បទចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទគឺមានទំនាក់ទំនងខ្ពស់ណាស់។ មេធាវីការពារក្តីប្រាកដណាស់នឹងមានឱកាសច្រើនក្នុងការធ្វើសេចក្តីសន្និដ្ឋាននៅចំពោះមុខអង្គជំនុំជម្រះ ចំពោះទម្ងន់នៃភ័ស្តុតាងដែលដាក់នៅក្នុងបរិបទនៃការចោទប្រកាន់ ដែលត្រូវដោះស្រាយនៅក្នុងសំណុំរឿង ០០២/០២។

១០- សហជនជាប់ចោទមានឱកាសច្រើនក្នុងការវាយតម្លៃពីភាពយថាភូត និងភាពជឿជាក់លើឯកសារភ័ស្តុតាងទាំងអស់ដែលបានទទួលយកនៅក្នុងសំណុំរឿង០០២/០១ តាមរយៈឯកសារនាពេលសវនាការស្តីពីការទទួលយក និងការពិភាក្សាដេញដោលយ៉ាងទូលំទូលាយ។ ជាងនេះទៀត សហជនជាប់ចោទមានសិទ្ធិពិនិត្យសាក្សី អ្នកជំនាញ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗដែលពាក់ព័ន្ធ។ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីអំពីសិទ្ធិតទល់ និងដេញដោល[23] គឺពិនិត្យលើអង្គហេតុដែលសិទ្ធិនោះត្រូវបានគេទទួលស្គាល់ និងមិនអាចសម្របសម្រួលបានដោយការសម្រេចដែលបានស្នើសុំ។

១១- ជាងនេះទៅទៀត ពុំមានការដាក់កម្រិតទៅលើភាគីណាមួយ មិនឲ្យលើកយកនូវភ័ស្តុតាងថ្មីៗបន្ថែមទៀតមកធ្វើជាភ័ស្តុតាងនៅក្នុងសំណុំរឿងលេខ០០២/០២ ដែលបដិសេធមិនទទួលស្គាល់ចំពោះតម្លៃភវនីយភាពនៃភ័ស្តុតាងជាឯកសារនីមួយៗដែលត្រូវបានទទួលយករួចហើយ នៅក្នុងសំណុំរឿងលេខ០០២/០១នោះឡើយ។ ចៅក្រមវិជ្ជាជីវៈទាំងឡាយអាចត្រូវបានសន្មតថាមិនធ្វើការពិចារណាលើភ័ស្តុតាងណាមួយដែលមិនមានការជាប់ទាក់ទងគ្នានោះ។ ការវាយតម្លៃជាថ្មីឡើងវិញ អំពីភាពជាប់ទាក់ទងនៃឯកសារ ឬចំណែកនៃសក្ខីកម្មសាក្សីនីមួយៗនោះ គឺមិនមានអត្ថន័យអ្វីឡើយ ជាជាងរៀបចំសំណុំរឿង ដែលដំណើរការវាយតម្លៃឡើងវិញដូចនេះ អាចប្រើពេលច្រើនហួសប្រមាណ។ លើសពីនេះ ដោយសារតែដីកាដំណោះស្រាយបានចោទប្រកាន់ថា រាល់ឧក្រិដ្ឋកម្មទាំងអស់ដែលបានចោទប្រកាន់សុទ្ធតែស្ថិតនៅក្នុងសហឧក្រិដ្ឋកម្មរួមតែមួយ គ្មានភ័ស្តុតាងណាមួយក្នុងចំណោមភ័ស្តុតាងដែលបានទទួលយករួចហើយនៅក្នុងសំណុំរឿងលេខ០០២/០១ មិនជាប់ពាក់ព័ន្ធជាមួយនឹងបទចោទប្រកាន់ដែលនៅសេសសល់នៅក្នុងដីកាដំណោះស្រាយនោះឡើយ។

### *ឃ. គេត្រូវកោះហៅសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ឡើងវិញម្តងទៀត ក្នុងករណីចាំបាច់ប៉ុណ្ណោះ*

[23] **E302/2** ចម្លើយតបរបស់ នួន ជា , កថាខណ្ឌ៥-៦។ **E302/1** ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌ៣៦។

១២- មេធាវីការពារក្ដី ខៀវ សំផន បានដាក់ជូនថា នីតិវិធីដែលបានប្រើប្រាស់នៅក្នុងសំណុំរឿង ០០២/០១ សម្រាប់ការទទួលយកភស្តុតាងនានាដែលជាសក្ខីកម្ម គួរត្រូវបានធ្វើឡើងវិញទាំងស្រុង ដើម្បីចៀសវាងនូវការធ្វើយុត្តិកម្មលើការកោះហៅសាក្សីបែបនោះឡើងវិញ[24]។ សហព្រះរាជអាជ្ញាធ្វើការអះអាងថា ការអនុញ្ញាតឱ្យមានការកោះហៅអ្នកជំនាញ សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីឡើងវិញ ក្នុងករណីដើម្បីផលប្រយោជន៍នៃយុត្តិធម៌ អាចរារាំងភាពច្រំដែលមិនចាំបាច់ និងអាចសម្រួលដល់ដំណើរការនីតិវិធីឆាប់រហ័ស។ ការចាប់ផ្ដើមទទួលយកភស្តុតាងជាថ្មីម្ដងទៀត អាចមានការពន្យារពេលសវនាការឱ្យហួសពីការចាំបាច់ ដោយហេតុថាភស្តុតាងគាំទ្រធាតុផ្សំជាមូលដ្ឋានដែលមានលក្ខណៈធម្មតាចំពោះឯកសារក្នុងសំណុំរឿង០០២ (ដូចជា ប្រវត្តិសាវតារនៃកម្ពុជាប្រជាធិបតេយ្យ តួនាទីរបស់ជនជាប់ចោទ ការគ្រប់គ្រងរដ្ឋបាល ការប្រាស្រ័យទាក់ទង និងរចនាសម្ព័ន្ធយោធា ព្រមទាំងអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម របស់ បកក)[25]។ វាមិនមែន ជាបន្ទុកធ្ងន់ហួសពីការចាំបាច់នោះទេ ក្នុងការរំពឹងថាភាគីត្រូវផ្ដល់មូលហេតុថាតើ ហេតុអ្វីបានជាអ្នកជំនាញ សាក្សី ឬដើមបណ្ដឹងរដ្ឋប្បវេណីមួយចំនួន ដែលបានផ្ដល់សក្ខីកម្មរួចហើយនៅចំពោះមុខជនជាប់ចោទម្នាក់ៗ និងត្រូវបានមេធាវីការពារក្ដីសួរដេញដោលរួចហើយ គួរត្រូវបានធ្វើការកោះហៅឡើងវិញម្ដងទៀតនោះ។ មេធាវីការពារក្ដី ខៀវ សំផន អះអាងថា ការបង្ហាញខ្លួនរបស់សាក្សីដដែលៗជាថ្មីឡើងវិញ និងដែលចំណាយពេលវេលានេះ គឺជាការវិលទៅរកការបំបែកកិច្ចដំណើរការនីតិវិធីឡើងវិញ ដោយចៀសមិនរួចឡើយ[26] ប៉ុន្តែ ពួកគាត់ខកខានមិនបានធ្វើយុត្តិកម្មទេ ហេតុអ្វីបានជាចាំបាច់ត្រូវការធ្វើដដែលឡើងវិញ។

១៣- សហព្រះរាជអាជ្ញា មិនមែនមិនយល់ព្រមទៅនឹងការដាក់ជូនរបស់មេធាវីការពារក្ដី នួន ជា នោះទេ ដែលថា គេគួរកោះហៅសាក្សីឡើងវិញម្ដងទៀត នៅក្នុងកាលៈទេសៈដែលវា "បម្រើឱ្យគោលដៅ

---

[24] **E302/1**, ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌ៣៥។

[25] **E124/7.3**, ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿងលេខ០០២/០១ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចអំពីសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា ក្នុងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿងលេខ ០០២/០១ (E163)។

[26] **E302/1**, ចម្លើយតបរបស់ ខៀវ សំផន, កថាខណ្ឌ៣៤, ដោយបានលើកឡើងពី **E284/4/8** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣ ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី"), កថាខណ្ឌ ៣៨-៣៩។

របស់អង្គជំនុំជម្រះនៃការវាយតម្លៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៅក្នុងករណី០០២/០២"[27]។ ការណ៍នេះមិនមែនមិនត្រូវគ្នាទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញានោះទេ ដែលថាសាក្សីនានាគួរត្រូវបានកោះហៅឡើងវិញម្តងទៀត បើបានបម្រើដល់ផលប្រយោជន៍នៃយុត្តិធម៌[28]។ ប្រសិនបើភាគីអាចបង្ហាញថា អ្នកជំនាញ សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធរូបណាមួយ មិនត្រូវបានអនុញ្ញាតឲ្យគេតាំងសំណួរដេញដោល ពាក់ព័ន្ធទៅនឹងសំណុំរឿង០០២ ហើយថាបុគ្គលណាមួយមានលទ្ធភាពអាចផ្តល់ព័ត៌មានបន្ថែម ដែលអង្គជំនុំជម្រះអាចនឹងចេញដីកាបង្គាប់កោះហៅពួកគាត់ឡើងវិញម្តងទៀត[29]។ សហព្រះរាជអាជ្ញាមិនមែនស្វែងរកធ្វើការដាក់ "លក្ខណៈវិនិច្ឆ័យ" ដល់សាក្សីទាំងនេះទេ ក៏ប៉ុន្តែគ្រាន់តែអនុវត្តវិធានជាធរមាន ដែលបានតម្រូវឲ្យភ័ស្តុតាងត្រូវមានការពាក់ព័ន្ធ និងមិនច្រំដែលតែប៉ុណ្ណោះ។

### *ង. នីតិវិធីកោះហៅឡើងវិញម្តងទៀតដែលបានស្នើសុំនេះ អាចលើកស្ទួយឲ្យមានសវនាការមួយប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស*

១៤- មេធាវីការពារក្តី ខៀវ សំផន ស្វែងរកការបដិសេធថា ការអះអាងរបស់សហព្រះរាជអាជ្ញាមិនមានខ្លឹមសារ ដែលថាពេលវេលាតម្រូវសម្រាប់ធ្វើសវនាការលើសំណុំរឿង០០២/០២ នឹងត្រូវកើនទ្វេ បើភ័ស្តុតាងពីសំណុំរឿង០០២/០១ ត្រូវបានធ្វើដដែលឡើងវិញ។ សហព្រះរាជអាជ្ញាកត់សម្គាល់ឃើញថា ការណ៍នេះគឺជាការប៉ាន់ស្មានមួយដែលស៊ីពេលតិចតួច ហើយថាមិនអាចទំនាស់មួយសមហេតុផលទេ ដែលថាចំនួននៃពេលវេលាសវនាការនឹងត្រូវកើនឡើងយ៉ាងខ្លាំង បើភ័ស្តុតាងពីសវនាការទីមួយ មិនត្រូវបានទទួលយកនោះ។ សូម្បីតែមេធាវីការពារក្តី ខៀវ សំផន ទទួលសារភាពថាសំណើរបស់ពួកគាត់សុំឲ្យធ្វើការចាប់ផ្តើមនូវកិច្ចដំណើរការនីតិវិធីឡើងវិញ អាចកាត់បន្ថយនូវភាពឆាប់រហ័សនៃសវនាការដោយចៀសពុំរួចឡើយ[30]។ ផ្នែកដែលចំណាយពេលវេលាច្រើនបំផុតនៃសំណុំរឿង០០២/០១ គឺសវនាការលើសាក្សី និងអ្នកជំនាញទាំងឡាយ ដែលបានផ្តល់សក្ខីកម្មលើ

---

[27] **E302/2** ចម្លើយតបរបស់ នួន ជា, កំណត់សម្គាល់*ខាងលើ* លេខ២ ត្រង់កថាខណ្ឌ៤។

[28] **E302** សេចក្តីសន្និដ្ឋានរបស់ កសព កំណត់សម្គាល់*ខាងលើ* លេខ១ ត្រង់កថាខណ្ឌ៨ ដោយបានលើកឡើង **E267/3** សេចក្តីសម្រេចលើសំណើសុំកោះហៅសាជាថ្មីដើមបណ្តឹងរដ្ឋប្បវេណី TCCP-187 និងសុំឲ្យពិនិត្យឡើងវិញលើបែបបទពាក់ព័ន្ធនឹងសក្ខីកម្មស្តីពីការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសំណើ និងចម្លើយតបនានាដែលពាក់ព័ន្ធ (E240, E240/1, E250, E250/1, E267, E267/1 និង E267/2), ២ ឧសភា ២០១៣, កថាខណ្ឌ២០។

[29] **E302** សេចក្តីសន្និដ្ឋានរបស់ កសព, កថាខណ្ឌ ៨-៩។

[30] **E302/1** ចម្លើយតបរបស់ ខៀវ សំផន, ដដែលដូចខាងលើ ត្រង់កថាខណ្ឌ៣៥។

បញ្ហានានាជាមូលដ្ឋានរួម ដូចជា តួនាទីរបស់ជន ជាប់ចោទ គោលនយោបាយ និងរចនាសម្ព័ន្ធរបស់ បកក និងរបបកម្ពុជាប្រជាធិបតេយ្យជាដើម។ (សក្ខីកម្មរបស់ពួកអតីតកម្មាភិបាល និងអ្នកជំនាញ បែបដូច្នេះ តម្រូវឲ្យមានថ្ងៃសវនាការសរុបចំនួន១១០,៧៥ថ្ងៃ ដោយប្រៀបធៀបទៅនឹងសវនាការ ចំនួន២០ថ្ងៃ សម្រាប់ការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ដែលទាក់ទងទៅនឹងការ ជម្លៀសដោយ បង្ខំចំនួនពីរដង និងទាក់ទងទៅនឹងទួលពោធិ៍ជ្រៃ)។ ការស្តាប់ឡើងវិញនូវរាល់សាក្សី និងអ្នកជំនាញបែបដូច្នេះ អាចជាការបន្ថែមចំនួនខែដោយមិនចាំបាច់ ដើម្បីបញ្ចប់សវនាការទីពីរនេះ ព្រមទាំងបណ្តាលឲ្យមានជាកិច្ចដំណើរការនីតិវិធីមួយដែលមានលក្ខណៈច្រំដែល ដែលអាចធ្វើឲ្យ បរាជ័យដល់សេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា សំណុំរឿង០០២/០១ ត្រូវយក ធ្វើជា "មូលដ្ឋាន" សម្រាប់សវនាការលើកក្រោយៗទៀត។

១៥- លើសពីនេះ ពីមុនមក មេធាវីការពារក្តី ខៀវ សំផន ធ្លាប់បានទទូចថា "អង្គជំនុំជម្រះសាលាដំបូង ត្រូវតែបំពេញកាតព្វកិច្ចក្នុងការធានាថា សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះ ក្នុង ពេលវេលាមួយសមរម្យ ត្រូវបានគោរព"[31]។ ភាពច្រំដែលមិនចាំបាច់នៃភ័ស្តុតាងដែលបានស្តាប់រួច ហើយនៅក្នុងសំណុំរឿង០០២/០១ ចូលទៅក្នុងសំណុំរឿង០០២/០២ ជាហានិភ័យប៉ះពាល់ដល់ សិទ្ធិ របស់ជនជាប់ចោទទាំងពីរនាក់ ក្នុងការទទួលបានសវនាការមួយឆាប់រហ័ស។

១៦- ចំពោះមូលហេតុទាំងឡាយខាងលើ សហព្រះរាជអាជ្ញាស្នើដល់អង្គជំនុំជម្រះឲ្យទទួលយកសំណើ របស់មេធាវីការពារក្តីដែលទាក់ទងនឹងការប្រើប្រាស់ភ័ស្តុតាង និងការកោះហៅសាក្សី នានា ពីក្នុងសំណុំរឿង០០២/០១ឡើងវិញ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៤ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញា | | [signature] |

[31] **E163/5/1/9** ចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២/០១, ៣០ វិច្ឆិកា ២០១២។